**ឧបសៅសង្ហា**

# ព្រលឹងជាតិខ្មែរគឺអ្វី ?




កូនខ្មែរ

## សាកល្បងពិចារណា

ខ្មែរយើងតែងតែមាន មោទនភាព អំពីអតីតកាលជាតិ ប្រកបដោយកិត្តិនុភាព, ជាពស្តុតាង,យើងឃើញថា តាំងពីស្រុកខ្មែរ បានទទួលឯករាជ្យពីបារាំងមក, អ្នកដឹកនាំខ្មែរគ្រប់របបនយោបាយ តែងតែយក ប្រសាទអង្គរវត្តជាបដិរូបជាតិខ្មែរ។ លើទង់ជាតិ របស់ប្រជាជាតិខ្មែរ, គេតែងយករូបប្រាសាទអង្គរវត្ត ទុកជាវត្ថុដ៏ប្រសិទ្ធិ សំរាប់ធ្វើអច្ចាវ៍ទ(ការគោរព), រំលឹកជាកំណត់ការចងចាំ នៃភាពថ្កុំថ្កើងខ្មែរពីអតីតកាល។ តែយើងដឹងថា អង្គរវត្ត ត្រូវបានអ្នកដឹកនាំខ្មែរយើង បានបោះបង់ចោល ហើយទុកជាកន្លែងឧត្បាតសំរាប់ជាតិខ្មែរ :

លើកទី១, យោងលើ ឯកសារព្រះរាជពង្សាវតារខ្មែរ[1], នៅក្នុងផែនដី ព្រះបាទអង្គជ័យ ឬ ព្រះបាទត្រសក់ផ្អែម (១៣៤០-១៣៤៦) មានចារថា ក្នុងបុរាណកាល មានស្តេចខ្មែរមួយអង្គព្រះនាម « សេណរាជ » ទ្រង់សំរេចចិត្ត ចាកចេញពីមហានគរ មកសាងព្រះរាជវាំង នៅក្បែរភ្នំប្រសិទ្ធិ។ ទោះបី ក្នុងឯកសារប្រវត្តិសាស្ត្រនេះ គេឥតបានបញ្ជាក់ឲច្បាស់ពីហេតុ នៃការដូរ រាជធានីនោះក៏ដោយ តែតាមការយល់របស់យើងផ្ទាល់ គឺគ្មានអ្វីក្រៅពី រាជាធានីមហានគរលែងមាន ភាពជាបូជនីយដ្ឋាន មិនតែប៉ុណ្ណោះ វាក្លាយជាទី កន្លែងអសន្តិសុខ សំរាប់របបដឹកនាំជាតិ ជំនាន់នោះ

[1] តាមឯកសារ ដំកល់ទុក ក្នុងបណ្ណាល័យព្រះបរមរាជវាំង, សៀវភៅក្បាលទី៣,លេខ៥៣,ទំព័រ៦៨។

ផង។ ស្ដេចអង្គនេះហើយ ដែលតាត្រសក់ផ្អែមបានធ្វើឃាតដោយចៃដន្យ ក្នុងចំការត្រសក់ផ្អែម របស់គាត់ ហើយក្រោយមក ត្រូវបានសេនាបតីមន្ត្រីទាំងពួង នាំគ្នាអញ្ជើញ តាត្រសក់ផ្អែម ឲឡើងសោយរាជ្យសម្បត្តិបន្ត។ បន្ទាប់មកព្រះបាទត្រសក់ផ្អែម បានសម្រេចចិត្ត លើករាជធានីពីភ្នំប្រសិទ្ធិ មកតាំងនៅមហានគរវិញ។ តាមឯកសារប្រវត្តិសាស្ត្រខ្មែរ ព្រះបាទសេណរាជ ជាមហាក្សត្រចុងក្រោយបំផុត នៃវង្សត្រកូលក្សត្រមហានគរ។ តាមឯកសារប្រវត្តិសាស្ត្រផ្សេងទៀត ចារទុកលើ សិលាចារឹកថាស្ដេចចុងក្រោយបង្អស់ នៃសម័យអង្គរគឺ ព្រះបាទជ័យវរ្ម័នទី៩ (១៣២៧-១៣៤០) ស្ដេចអង្គនេះហើយ ដែលត្រូវតាត្រសក់ផ្អែមធ្វើឃាត, បន្ទាប់មកឃាតករនេះ បានឡើងគ្រងរាជ្យ នៅឆ្នាំ១៣៤០។ ក្នុងចំណុចនេះ អ្នកប្រវត្តិសាស្ត្រមានការអល់អែកយ៉ាងខ្លាំងមិនដឹងថា ត្រូវដាក់អង្គស្ដេចណា ឲសោយរាជ្យ តពីព្រះបាទជ័យវរ្ម័នទី៩ ដែលគេមិនដឹងច្បាស់ផងថា ស្ដេចអង្គនេះបានសោយទិវង្គតនៅឆ្នាំណាពិតប្រាកដផង។ សេចក្ដីរញ្ជួរនេះ បញ្ជាក់បង្ហាញថាក្នុងសម័យនោះ ច្បាស់ជាមានកលិយុគអ្វីមួយ ឬ បដិវត្តន៍ កើតឡើងក្នុងមហានគរ ដែលនាំឲមានការកាច់ស្នាម

ប្រវត្តិសាស្ត្រជាតិ បន្តឲ្យច្បាស់ពី រជ្ជកាលព្រះបាទជ័យវរ្ម័នទី៩ ដែលជា ស្តេចចុងក្រោយបង្អស់ នៃសម័យអង្គរ[2]។

ការបោះបង់មហានគរ លើកទី២ គឺ ព្រះបាទពញាយ៉ាត (១៣៨២-១៤២៧), ទ្រង់បានសម្រេចចិត្ត លើករាជធានីពីមហានគរ មកតាំងនៅក្នុងស្រុកបាសាន ក្នុងអំឡុងឆ្នាំ ១៣៨២។ បន្ទាប់មកទៀត ទ្រង់បានលើករាជធានីមកតាំងនៅ ភូមិឫស្សីកែវ, ក្នុងខេត្តភ្នំពេញ, ដោយសារនៅស្រុកបាសាន ជាដំបន់លិចទឹកជ្រៅក្រៃលែង ដែលនាំឲមានក្តីលំបាកជាច្រើន ដើម្បីកសាងរាជធានី។

ការប្តូររាជធានីលើកនេះ ជាការដូរជាស្ថាពរ ព្រោះស្តេចខ្មែរបន្តក្រោយៗមក រហូតមកដល់បច្ចុប្បន្នកាល មិនដែលមានព្រះរាជាណាម្នាក់ បានលើករាជធានី វិលត្រឡប់ទៅតាំងនៅ មហានគរវិញនោះឡើយ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា ការដូរទីកន្លែងរាជធានីនេះ ជាការបញ្ចប់ជាស្ថាពរដែរ នៃរបបនយោបាយមហានគរខ្មែរ។ គួរដឹងដែរថា តើមានមូលហេតុអ្វី បានជាព្រះបាទពញាយ៉ាត សម្រេចចិត្តចាកចេញពីមហានគរ ?

តាមឯកសារប្រវត្តិសាស្ត្រ មូលហេតុមានច្រើន ដំបូងជាយុទ្ធសាស្ត្រយោធា។ ដូចយើងដឹងថា ព្រះបាទពញាយ៉ាត

---

[2] អ្នកប្រាជ្ញបរទេស មិនទុកព្រឹត្តិការណ៍ គាត្រេសក់ផ្អែម ជាប្រវត្តិសាស្ត្រក្នុងន័យវិទ្យាសាស្ត្រ តែគេមិនជំទាស់ដាច់ខាតនឹង ស្នាមព្រឹត្តិការណ៍ សរសេរដោយខ្មែរដែរ។

ជាវេរក្សត្រ (Roi victorieux) រំដោះស្រុកខ្មែរ ចេញពីការកាន់កាប់សៀម តែទ្រង់បែជាយល់ឃើញថា ជោគជ័យនេះជាជោគជ័យបំភាន់ភ្នែកតែប៉ុណ្ណោះ បើសិនជា ព្រះអង្គមិនដូរយុទ្ធសាស្ត្រការពារជាតិ។ ក្នុងគំនិតនេះ ទ្រង់យល់ថា មហានគរ ជាទីតាំងនៅក្បែរពេកទល់ដែនខ្មែរសៀម, ទីជិតនេះ នាំឲខ្មែរយើង មានការលំបាកជាច្រើនក្នុងយុទ្ធសាស្ត្រយោធា សំរាប់ការពារមហានគរ ព្រោះទ័ពសៀមអាចវាយប្រហាររាជធានីខ្មែរ តាមការលួចល្បក់បានងាយស្រួលណាស់ ដូច្នេះ ការដូរទីកន្លែងរាជធានីមកតាំងទី នៅឆ្ងាយពីទល់ដែនសៀម ជារបៀបរៀបការពារជាធម្មជាតិមួយ ដើម្បី ទុកពេលវេលាគ្រប់គ្រាន់ ឲព្រះអង្គកេណ្ឌកងទ័ព ដើម្បីតទប់នឹងវេរវេគ (កម្លាំងសត្រូវ) វាយលុកចូលដែនដីខ្មែរ។ ជាពិសេសទៅទៀត នៅក្នុងដំបន់មហានគរពេលនោះ លែងមានធនធានមនុស្សគ្រប់គ្រាន់ សំរាប់កេណ្ឌធ្វើទាហានផង និង ជាពលសេដ្ឋកិច្ច សំរាប់ការរស់នៅផង ព្រោះថា ដោយសារមានសង្គ្រាមជាច្រើនដងពេករវាងខ្មែរនិងសៀម នាំឲប្រជារាស្ត្រស្លាប់ច្រើនក្នុងសង្គ្រាម និង នាំគ្នារត់ចេញពីដំបន់មហានគ ដើម្បីរត់គេចពីការកេណ្ឌធ្វើទាហាន និង ខ្លាចទ័ពសៀមកេណ្ឌយកទៅស្រុកសៀម។

ចំពោះអ្នកស្រុករស់ក្នុងដំបន់មហានគរជំនាន់នោះ គេយល់ឃើញថា មហានគរ អស់មានលទ្ធភាព រក្សាសន្តិសុខ

ដល់ការរស់នៅ របស់គេទៀតហើយ។ និមិត្តរូប នៃ « ភាព ថ្កុំថ្កើង » ដែលធ្លាប់ជា ម្លប់នៃសេចក្តីសុខ បានដូរភាព ជាវាលសោះខ្យល់ សំរាប់ជីវភាពរស់នៅ ប្រកបទៅដោយ ការភិតភ័យ រង់ចាំតែ មហន្តរាយ ដែលនឹងអាចកើត ឡើងគ្រប់ពេលវេលា ឥតឲដំណឹងជាមុននោះឡើយ។ វុត្ត ការណ៏ (ហេតុដែលបាននិយាយរួចហើយ) នេះ ជាកត្តា ជំរុញឲ ព្រះបាទពញាយ៉ាត សម្រេចចិត្តចាកចេញពីមហា នគរ។ ម្យ៉ាងវិញទៀត ស្តេចខ្មែរ ក្នុងព្រះរាជវង្សតាត្រសក់ ផ្អែម ដែលមានពូជពង្សវង្សត្រកូលជារាស្ត្រ មិនសូវដែល មានការជំពាក់ចិត្តនឹងមហានគរនោះឡើយ ព្រោះជាទី កន្លែង របស់សន្តតិវង្សចាស់ និងជា ទីកន្លែង ដែលព្រះ រាជវង្សានុវង្សខ្មែរនោះ បានកសាងឡើង សំរាប់តែធ្វើការ បូជាថ្វាយដល់អាទិទេព នៃព្រាហ្មញ្ញសាសនា ដែលជា មនោគមវិជ្ជា នៃពួកព្រាហ្មណ៏បុរោហិតក្លិង្គ ខុសពីពុទ្ធ សាសនា ដែលជាសាសនាពិតរបស់ប្រជាពលរដ្ឋខ្មែរ។

ព្រះរាជវង្ស តាត្រសក់ផ្អែម ក្រោយពីបានទៅសោយរាជ្យ នៅមហានគរអស់ច្រើនរជ្ជកាល បានឃើញយល់ថា មហា នគរ ជាទីកន្លែងនាំឲមានការខូចប្រយោជន៏ច្រើន ដល់ ការដឹកនាំជាតិ ព្រោះទី១ជា និមិត្តរូប នៃ « រដ្ឋបព្វជា », ទី២ ជាទីតាំង ត្រូវការធនធានច្រើនណាស់ ជាប្រាក់ក្តី ជា មនុស្សក្តី ចំណាយ ដើម្បី ផ្គត់ផ្គង់ ជីវភាពរស់នៅ របស់អ្នក ស្រុក និង ការពារបូរី, ទី៣ មហានគរ តាមរូបភូមិសាស្ត្រ

លែងជាទីតាំងកណ្តាល នៃរាជាណាចក្រខ្មែរ ដូចកាលពីសម័យមហានគរ។
សូមជ្រាបថា ដោយយោងតាម សិលាចារឹក ដែលគេរកឃើញក្នុងភូមិភាគឥសាន នៃប្រទេសថៃសព្វថ្ងៃ គេដឹងថា ប្រជាពលរដ្ឋខ្មែរ តាំងពីសម័យចេនឡាមកម្លេះ (នៅពាក់កណ្តាល ស.វ.ទី៦ រហូតមកដល់ដើម ស.វ.ទី៩) បានគោរព ព្រះពុទ្ធសាសនាហិនយាន មុនក្លិង្គ ចូលស្រុកខ្មែរ។ ដូច្នេះឯងបានជាយើង សង្កេតឃើញថា ព្រហ្មញ្ញសាសនា មិនសូវមាន ឥទ្ធិពល មកលើប្រជាពលរដ្ឋខ្មែរច្រើននោះឡើយ ទោះបី សាសនានេះ ត្រូវវណ្ណៈអ្នកដឹកនាំខ្មែរ យកមកធ្វើជា សាសនារដ្ឋ សំរាប់វណ្ណៈខ្លួនគោរពបូជាក៏ដោយ។ យើងដឹងថា ក្នុងសម័យអង្គរ (ចាប់តាំងពីឆ្នាំ៨០២ រហូតមកដល់ឆ្នាំ១៣៥០ ?) ក្នុងរជ្ជកាល ព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៩) ទោះបី របបរាជានិយម ជំនាន់នោះ គោរពស្រឡាញ់ ពុទ្ធសាសនាយ៉ាងណាក៏ដោយ ក៏របបនេះ នៅតែរក្សា ទំនាមទំនាប់ព្រហ្មញ្ញសាសនា នៅក្នុងព្រះរាជវាំងដ៏ដែល ព្រោះគេយល់ឃើញថា ព្រហ្មញ្ញសាសនា មានអត្ថប្រយោជន៏ពីរយ៉ាងសំខាន់ សំរាប់វណ្ណៈអ្នកដឹកនាំ :
១. ព្រហ្មញ្ញសាសនា មានអត្ថរស ជាសាសនាផង និងជាក្បួនសំរាប់ដឹកនាំជាតិផង។ ក្នុងទិដ្ឋភាព ជាក្បួននេះហើយ ដែលរបបរាជានិយម ទុកអត្ថប្រយោជន៏ នៃមនោគមវិជ្ជាព្រាហ្មបុរោហិត ជាបោសិតកិច្ច (កិច្ចដែលត្រូវ

ចិញ្ចឹមបីបាច់រក្សា) របស់អ្នកដឹកនាំ។ ប៉ុន្តែគេបានបញ្ចូលបន្ថែម នូវទិដ្ឋភាពថ្មីមួយទៀត ក្នុងក្បួនដឹកនាំជាតិនោះ គឺ វិស័យសីលធម៌ ដែលជា វិស័យមួយសំខាន់របស់ព្រះពុទ្ធសាសនា។ ជំនឿលាយគ្នានេះនាំបង្កើត នូវលទ្ធិដឹកនាំថ្មីមួយ ដែលយើងតែងឮចាស់ទុំខ្មែរ និយាយថា « អ្នកដឹកនាំល្អ គឺអ្នកដឹកនាំប្រកបដោយព្រហ្មវិហារធម៌ » តាមលទ្ធិពុទ្ធសាសនា ព្រហ្មគឺជា ធម៌បន្សាត់បាប ឬ កំចាត់កិលេស។

ក្នុងលទ្ធិដឹកនាំថ្មី ដែលយកគោលព្រះពុទ្ធសាសនា ជាមូលដ្ឋាន លែងចាត់ទុកព្រះមហាក្សត្រ ជាអាទិទេពលើលោកកិយ ដូចក្នុងរបបរាជានិយម និយមព្រហ្មញ្ញសាសនាទៀតហើយ។ តួនាទី ព្រះមហាក្សត្រ គឺជា អ្នកការពារព្រះពុទ្ធសាសនា អ្នកដឹកនាំប្រជារាស្ត្រ ក្នុងជម្ន ដើម្បីសេចក្តីសុខ និង សេចក្តីចំរើន នៃសង្គមជាតិ។

២. ព្រហ្មញ្ញសាសនា មានការបែងចែក នូវវណ្ណៈក្នុងសង្គម ដែលជា ការបែងចែក ឈរលើ ការបែងចែកដាច់ស្រឡះ អំពីតួនាទី របស់វណ្ណៈនិមួយៗ សំរាប់រក នូវស្ថិរភាព ក្នុងសង្គម។ វណ្ណៈទាំងបួន មានដូចតទៅ គឺ : វណ្ណៈបព្វជិត (ព្រាហ្មណ៍) វណ្ណៈអ្នកដឹកនាំ (ក្សត្រិយ: ឬ ខត្តិយ:) វណ្ណៈអ្នកប្រកបវិជ្ជាជីវ:សេរី (វៃស្ស:ឬវេស្ស:) និង វណ្ណៈបាវបំរើ ឬ ខ្ញុំគេ (សូទ្រ: ឬសុទ្ទ:)។ វណ្ណៈនិមួយៗ ជាវណ្ណៈស្ងួពូជ ឥតអាចមានលទ្ធភាពដូរ ឬ ឆ្លងពី វណ្ណៈមួយ ទៅវណ្ណៈមួយបាន

នោះឡើយ។ តាមទិដ្ឋភាព នៃការរក្សាស្ថិរភាព ក្នុងសង្គម នេះហើយ ដែលយើងឃើញថា របបរាជានិយមខ្មែរ និយមពុទ្ធសាសនានៅតែរក្សារបៀប នៃរាជពិធីព្រហ្មញ្ញសាសនា នៅក្នុងវាំងជានិច្ច។ ការរក្សានេះ គឺជាការរក្សា នៃវង្សត្រកូលស្តេចក្នុងតួនាទី ជាអ្នកដឹកនាំជាតិផ្តាច់មុខ ស្របតាមការបែងចែកវណ្ណៈក្នុងព្រហ្មញ្ញសាសនា។ យើងឃើញថា ទោះបីតាត្រសក់ផ្អែម ដែលជា ស្តេចមានពូជ ជារាស្ត្រក៏ដោយ ហើយជា អ្នកគោរពពុទ្ធសាសនាគ្មានខ្ចោះផង ក៏ទ្រង់ នៅតែរក្សា ក្រុមព្រាហ្មណ៍បុរោហិត នៅក្នុងរាជវាំងជានិច្ច ព្រោះទ្រង់ ទុករបបរាជានិយម ជាប្រពៃណី និងជាគ្រឹះ របស់ជាតិខ្មែរ។ ក្នុងទស្សនៈនេះហើយ ដែលខ្មែរ តែងឮចាស់ទុំខ្មែរនិយាយថា « បើពេលណានគរឥតមានស្តេច គឺនឹងមានកើត នូវកលិយុគ ជាមិនខាន »។ ក្នុងទស្សនៈនេះដែរ ដែលវង្សត្រកូលស្តេច តែងទុកពូជអំបូរ របស់ខ្លួន ជា នរបតី (ម្ចាស់ នៃពួកមនុស្ស) ដែលមានប្រជារាស្ត្រជាខ្ញុំបំរើ។ ហេតុនេះឯងបានជា ខ្មែរទុកខ្លួនជា « ខ្ញុំ » មាន ស្តេច ជាម្ចាស់។ ប្រើពាក្យ « ខ្ញុំ » សំរាប់សំគាល់ នូវអត្ថិភាព របស់ខ្លួន។ ការប្រើពាក្យសំដីនេះ គឺជាបច្ចេកទេស សំរាប់វាយសតិរាស្ត្រ ឲទទួលស្គាល់ នូវនិស្ស័យរបស់ខ្លួនជា « ខ្ញុំ » របស់វណ្ណៈក្សត្រ ឬ អ្នកដឹកនាំជាតិ។ លទ្ធិដឹងនាំ របស់រាជានិយម និយមព្រះពុទ្ធសាសនា ដែលបានរៀបរាប់ខាងលើនេះ « ស្តេចស្រឡាញ់រាស្ត្រ រាស្ត្រមាន

សក្ការៈ (ស្នេហាខ្ពង់ខ្ពស់) ចំពោះស្តេច » ប្រហែលគ្រាន់ ជាទ្រឹស្តី ឬ ការឃោសនា របស់របបនយោបាយនេះតែប៉ុណ្ណោះ។ ត្រូវដឹងថា « ម្ចាស់ » និង « ខ្ញុំ » កើតមានក្នុងសង្គមខ្មែរពីការរួបរួម នៃវណ្ណៈពី គឺ ព្រាហ្មណ៍ និង ក្សត្រៈ ដើម្បីជញ្ជក់ផលប្រយោជន៍ពីវណ្ណៈសូទ្រៈ ដែលវណ្ណៈទាំងពីទុកជា កម្លាំងបាវបំរើ ដែលគេតែងហៅថា ពួជរាស្ត្រ ឬពួជខ្ញុំគេ។ ត្រូវដឹងដែរថា វណ្ណៈព្រាហ្មហ៍ និង ក្សត្រៈ ជាគូដៃតាមប្រយោជន៍ តែបែងចែក នូវមុខនាទីដាច់គ្នា : តួនាទីព្រាហ្មហ៍ គឺគោលការណ៍ ខាងសាសនា, តួនាទី ពួកក្សត្រៈ គឺគោលការណ៍ ខាងនយោបាយ។ ស្តេចត្រូវការព្រាហ្មណ៍បុរោហិត សំរាប់ ធ្វើវិធីទំនាក់ទំនងនឹង អាទិទេព។ បើគ្មានព្រាហ្មណ៍ បុរោហិត ជាអ្នករៀបវិធី, អាទិទេព ពុំអាច បរិភោគ ដង្វាយ របស់ស្តេច ថ្វាយជូននោះឡើយ ជាពិសេស ព្រះមហាក្សត្រ ត្រូវចំបាច់ មានព្រាហ្មណ៍បុរោហិតម្នាក់ ជាទីប្រឹក្សាផ្ទាល់ ដែលខ្មែរយើងហៅថា « ព្រះរាជគ្រូ » ជាអ្នក មានអំណាច សាសនាចក្រ អមព្រះមហាក្សត្រដែលជា អ្នកកាន់អំណាចអាណាចក្រ។ អំណាចទាំងពីរនេះ ជាអំណាច សំរាប់ដឹកនាំជាតិ របស់របបរាជានិយមនៅសម័យមហានគរ។

ត្រឡប់មកនិយាយអំពី ការបោះបង់មហានគរវិញ,យើងដឹងថា ពីសតវត្សមួយទៅសតវត្សមួយកន្លងទៅ រហូតមកដល់ចុងសតវត្សទី១៩ ប្រជារាស្ត្រខ្មែរ ភ្លេចឈឹងអំពី

អត្តភាព នៃសម័យរុងរឿង របស់ប្រជាជាតិខ្លួន។ ការភ្លេចពីអតីតកាលនេះ ជាការបាត់សម្បជញ្ញៈជាតិ ក្នុងរយៈពេល ដ៏យូរលង់មួយ ដែលនាំឲយើង សួរជាសំនួរថា តើសង្គមខ្មែរមហានគរ និង សង្គមខ្មែរបាត់សម្លជញ្ញៈជាតិ ជាសង្គមខ្មែរតែមួយនោះដែរនោះឬទេ ?

មកដល់ចំណុចនេះ យើងអាចសួរជា សំនួរមួយទៀតថា អ្វីជា « សម្បញ្ញៈជាតិ ? »។

សម្បញ្ញៈជាតិជា អត្តរស របស់សង្គមមួយ ដែលជា អសម្ភារៈ (ឥតរូប) ដែលមានចិន្តា (pensant) ដែលខ្មែរតែងហៅថា « ព្រលឹងជាតិ »។ នៅក្នុងខណៈមួយដែលសង្គមបាត់ព្រលឹងជាតិ ខណៈនោះ សង្គមនោះ ច្បាស់ជាមិនដូចគ្នានឹងសង្គម ដែលមានព្រលឹងជាតិនោះទេ ដែលជាគំនិតសំរាប់សំគាល់ នូវអត្តសញ្ញណ របស់ប្រជាជាតិ។

តើប្រជាជាតិ ជាអ្វី ? ប្រជាជាតិមាន អត្តរស់បីយ៉ាង :

១. ទឹកដីនិងប្រជាពលរដ្ឋ (corps),

២. បញ្ញាបានសម្រេចមួយ (intelligencesFinies),

៣. ជំនឿលើគំនិតខ្ពង់ខ្ពស់មួយ ដូចជា សាសនា ឬ មនោគមវិជ្ជា ដែលគេយល់ឃើញថាជា ធម្មាត្រិះ របស់មនុស្ស។

ប្រលឹងជាតិជា បញ្ញាបានសម្រេច ដែលជា បញ្ញាកើតមានឡើងបន្តៗគ្នា តាំងពីប្រជាជាតិ មានកំណើតមកម្លេះ ដូច្នេះក្នុងការវិវត្តន៍ របស់សង្គមជាតិ ពីដំណាក់កាលមួយ ទៅដំណាក់កាលមួយ តែងតែមាន ខណៈកាល

សម្រេចមួយ ដែលជា បញ្ហាបានសម្រេចមួយ សំរាប់ពង្រឹងគ្រឹះប្រជាជាតិ។ ការបូករួម ខណៈកាល ជាបន្តនិមួយៗ រួមបានជា បញ្ហាបានសម្រេច របស់ប្រជាជាតិ។

យើងដឹងថា ប្រជាជាតិខ្មែរ ក្នុងរយៈពេលដ៏យូរលង់មួយ (៥សតវត្ស) មានដំណើរ បាត់ នូវការវិវត្តន៍ នៃបញ្ហាជាតិ គឺ បាត់ព្រលឹងជាតិ។ ក្នុងខណៈកាល ដែលបាត់ព្រលឹងជាតិ យើងសង្កេតឃើញ តាមស្នាមប្រវត្តិសាស្រ្តថា ការរស់នៅរបស់ប្រជាពលរដ្ឋ គឺគាត់រស់ ក្នុងទំនាមទំលាប់មួយគ្មានអភិវឌ្ឍន៍ភាព នៃបញ្ហាជាតិ ដែលនាំឲជាតិខ្មែរយើងធ្លាក់ក្នុងអន្តង្គត រហូតស្ទើរតែក្ស័យជីវិតជាតិតែម្តង។ ជាឳកាស ងាយស្រួលដល់ប្រទេសជិតខាង ធ្វើនយោបាយវាតទីកដី ដែលជា ការវិនាសដល់ប្រជាជាតិ និង ជាតិសាសន៍ខ្មែរ : « បាត់ព្រលឹងជាតិ គឺបាត់អាវុធបញ្ញា សំរាប់ការពារទឹកដីជាតិ »។ យើងដឹងថា វិនាដកម្មខ្មែរនេះ ត្រូវបាន អ្នកកវីបុរាណខ្មែរជាច្រើន លើកយកមកតែងជាកំណាព្យ សំរាប់ទុកជាមេរៀន សំរាប់ប្រជាលរដ្ឋខ្មែរ : ឧទាហរណ៍ ដូចជា បន្ទាំក្រុមង៉ុយ ជាអាទិ៍។ វិនាដកម្មនេះទៀត ដែលជាហេតុ នាំឲខ្មែរ យល់ឃើញថា សិទ្ធិសញ្ញាអាណាព្រាបាលបារាំង នៅឆ្នាំ១៨៦៣ ជាការសង្គ្រោះជាតិខ្មែរ ពីសេចក្តីស្លាប់ ទោះបីសិទ្ធិសញ្ញានេះ គ្រាន់តែការដូរអ្នកត្រួតត្រាខ្មែរ ពីសៀម មកបារាំងក៏ដោយ។

គួរយើងធ្វើការពិចារណាដែរ អំពីធាតុ នៃរដ្ឋ របស់ប្រជាជាតិខ្មែរ ព្រោះធាតុ របស់រដ្ឋនេះ នាំឲយើងយល់កាន់តែជ្រៅ លើសារជាតិ នៃរបៀបដឹកនាំជាតិ របស់អ្នកដឹកនាំខ្មែរ និង ឧបាទាន នៃចិត្តវិជ្ជា របស់ប្រជាពលរដ្ឋខ្មែរ ចំពោះប្រជាជាតិខ្លួន។

យើងដឹងថា ធាតុ របស់រដ្ឋ មានច្រើនបែបយ៉ាង៖

រដ្ឋ-ប្រជាជាតិ, ប្រជារាស្ត្រ-ប្រជាជាតិ និង វប្បធម៌-ប្រជាជាតិ។

**រដ្ឋ-ប្រជាជាតិ** ជាប្រជាជាតិ មានគ្រឹះ លើរូបភូមិសាស្ត្រនិយម ដែលផ្ទុយស្រឡះ ពីគ្រឹះ « **ប្រជារាស្ត្រ-ប្រជាជាតិ** » ដែលមាន សារជាតិ ជាអត្តសញ្ញាណ នៃរដ្ឋ គឺ: ភាសារជាតិ, បវេណី និង សាសនា។ ចំណែកឯ **វប្បធម៌-ប្រជាជាតិ** ជាប្រជាជាតិ មានវប្បធម៌ ជាគ្រឹះ របស់សង្គម ដូចជាទម្លាប់, ឫកពា, ចរិត, ប្រតិកម្មរួមគ្នា នៃប្រជារាស្ត្រក្នុងការរស់នៅជាធម្មតា។

យើងសួរថា តើប្រជាជាតិខ្មែរ ជាប្រជាជាតិ បែបណា ?

ខ្មែរតែងតែបែងចែកប្រជាជាតិខ្លួន ជាដំបន់ភូមិសាស្ត្រ ដូចជា និយាយថា ខ្មែរលើ, ខ្មែរកណ្ដាល និង ខ្មែរក្រោម។ តាំងតែពីសម័យ នគរហ្វូណន់ (ឈ្មោះចិនហៅ) ដែលជាពាក្យកំឡាយពី « នគរភ្នំ » ក៏ខ្មែរបានយកពាក្យទីកន្លែងភូមិសាស្ត្រ សំរាប់ដាក់ឈ្មោះ ឲនគរខ្លួនដែរ។ ឯចំណែក « នគរចេនឡា » (ឈ្មោះចិនហៅមិនច្បាស់) បើតាមការ

ស្រាវជ្រាវ របស់លោកបណ្ឌិត ម.ត្រាណេ ពាក្យចេនឡាន នេះ ជាពាក្យ កំឡាយពីពាក្យខ្មែរថា « ជាន់លើ »។ ការ អះអាងនេះ លោក ត្រាណេ ផ្អែកទៅលើសក្ខីកម្ម របស់ជន ជាតិខ្មែរ រស់នៅខេត្ត សុរិន្ទ្រ បូរីរម្យ និង អ៊ូប៊ុន ក្នុងដំបន់ ខ្ពង់រាប់ នៃជ្រលងទន្លេមូល នៅខេត្តនគររាជសីមា ស្ថិត នៅម្ខាងទៀត នៃជួរភ្នំដងរែក។ ពួកគេ មានទម្លាប់តាំង ខ្លួន ជាខ្មែរលើ ដោយប្រៀបផ្ទឹមខ្លួនគេនឹងជនជាតិខ្មែរ ក្រោម ដែលថៃហៅថា ខម។ លោក ត្រាណេ សរសេរបន្ថែម ថា : « ដោយចោទសួរន័យ របស់ពាក្យ (ជាន់លើ) ពួកខ្មែរ នៅខេត្តសុរិន្ទ្រ បានឆ្លើយតប និងអះអាងថា ដូនតា របស់គេ ក៏និយមពាក្យនេះដែរ គឺសំរាប់សំដៅទៅលើខ្មែរ រស់នៅជួរភ្នំដងរែក ជាដែនដីជាន់លើ ដែលគេទុកជា ស្រុកកំណើត របស់ពូជពង្សវង្សត្រកូលរបស់ពួកគេ ដែល ជាខ្មែរលើ »។

យើងសង្កេតឃើញ មកទៀតថា នៅពេល ដែលនគរ « ជាន់លើ » ឬ « ចេនឡា » បែកជា រដ្ឋពីរ, ខ្មែរយើងនៅ តែយក គោលរូបភូមិសាស្ត្រ សំរាប់សំគាល់ នូវដំបន់ នៃរដ្ឋ ដែលបំបែកជាពីរ គឺ « ចេនឡាទឹក » និង « ចេនឡា គោក »។ ក្នុងបច្ចុប្បន្នកាលនេះទៀត ខ្មែរនៅតែបែង ចែកប្រជាជាតិខ្លួន ជាដំបន់ភូមិសាស្ត្រដដែល គឺមាន : ខ្មែរលើ (ទឹកដីខ្មែរ ដែលប្រទេសថៃ គេភ្ជាប់ក្នុងប្រទេស គេ), ខ្មែរកណ្ដាល (ទឹកដីស្រុកខ្មែរបច្ចុប្បន្ន) និង ខ្មែរ

ក្រោម (ទឹកដីកូសាំងស៊ីន ដែលយៀកណាម គេភ្ជាប់ក្នុងប្រទេសគេ)។

តាមស្នាមប្រវត្តិសាស្ត្រ ប្រជាជាតិខ្មែរ ជាប្រជាជាតិមួយកើតមានឡើង ពីការប្រជុំផ្តុំនៃរដ្ឋតូចៗជាច្រើន ដែលបានចុះចូល តាមការបង្ខំក្តី តាមចេតនាក្តី ក្នុងរដ្ឋធំជាងគេមួយ។ ខ្មែរយើងនិយមហៅនគរថា ស្រុក ដូចយើងហៅប្រទេសខ្លួនថា « ស្រុកខ្មែរ » នោះឯង[3]។ ពាក្យ « ចៅហ្វាយស្រុក » គឺជា ចៅហ្វាយរដ្ឋ (Chef de l’Etat) មាន អំណាចផ្តាច់ការ ដែលជា អំណាចតពូជ លើទឹកដីដែលឋិតនៅក្រោមការត្រួតត្រារបស់ខ្លួន។ ទោះបីខ្លួនឋិតនៅក្រោមអំណាចមជ្ឈិមក៏ដោយ តែអំណាចអធិរាជនោះតែងតែទុក ស្វ័យភាពឲចៅហ្វាយស្រុកនិមួយៗ ត្រួតត្រាស្រុក តាមឆន្ទ: របស់អ្នកត្រួតត្រានោះ។

ក្នុងរាជពង្សាវតារខ្មែរ ក្នុងរាជព្រះឥន្ទរាជា ជាស្តេចសៀមត្រួតស្រុកខ្មែរ ក្នុង គ.ស ១៣៨០ (ឯកសារ របស់លោក អេង សុត,ទំព័រ៤៧) បានសរសេរអំពី ការចោទសួរជាសំនួរនៃព្រះបរមរាជា, ស្តេចសៀម, ដែលត្រូវជា បិតាព្រះឥន្ទរាជា, ទៅមន្ត្រីខ្មែរម្នាក់ ដែលជាអ្នកនាំព្រះអង្គដើរមើលបូរីមហានគរ ក្រោយពី ព្រះអង្គឈ្នះសង្គ្រាម។ នៅពេលនោះ, ព្រះអង្គឃើញមានប្រសាទ និង រោងទង មានផ្ទឹមថែរ

[3] ខ្មែរ មិនប្រើពាក្យ ប្រទេសខ្មែរ នោះទេ គឺប្រើពាក្យ ស្រុកខ្មែរ។ បើយកពាក្យប្រទេសមកប្រើ គឺ ប្រើថា ប្រទេសកម្ពុជា។

ខ្វាក់ខ្វែងច្រើនជាន់ ច្រើនអន្លេ, ទើបទ្រង់ត្រាសសួរមន្ត្រីខ្មែរថា : « តើទីកន្លែងនេះ ជាកន្លែងព្រះរាជបុត្រ ឬ ជាទីកន្លែងព្រះអគ្គមហេសី ឬ ជាទីកន្លែងអ្វី ? »។ មន្ត្រីខ្មែរក្រាបទូលថា : « ទីនេះ ហៅថា ប្រសាទ ១៥៥ ល្វែង និងរោងទង, រោងជួង, ដំណាក់ពិសេស, ស្រះស្រង់រងថ្លា, សួនច្បារ, ផ្កាដំណាំ, និងកំផែងខ្វាត់ខ្វែង, ច្រើនថ្នល់ច្រើនថ្នាក់នេះ ជាប្រសាទ សម្រាប់ព្រះរាជបុត្រក្សត្រ គ្រប់នគរជាចំណុះ, មាន ១៥៥ នគរ ដែលព្រះអង្គតែងយក ព្រះរាជបុត្រឲមកនៅបម្រើ តាងព្រះអង្គគ្រប់នគរ។ ក្នុងសម័យខ្មែររុងរឿង ព្រះមហាក្សត្រខ្មែរ ទ្រង់គង់នៅប្រាសាទបាយ័ន ឯចំណែក ព្រះរាជបុត្រ ទ្រង់គង់ក្រសាលនៅប្រាសាទពិមានអាកាស។ ព្រះមហាក្សត្រខ្មែរ ដែលបានបង្វែរនគរតូច ទៅជាវត្តនោះ ទ្រង់ព្រះនាមព្រះបាទបទុមសុរិយោវង្សា។ ការបង្វែងនេះ គឺសំរាប់ តម្កល់ ព្រះត្រៃបិដក នៅនគរតូច ឬ អង្គរវត្ត »។ ព្រះចៅបរមរាជាទ្រង់ជ្រាបហើយ ទ្រង់ព្រះអំណរណាស់ : តមក ទ្រង់ត្រាស់ឲមន្ត្រីសៀម៨នាក់ នៅរក្សាព្រះនគរខ្មែរ ជាមួយនឹងព្រះឥន្ទរាជា ជាព្រះរាជបុត្រ។ ព្រះអង្គឲនិមន្តព្រះពុទ្ធរូបមាស, ប្រាក់, សំរិទ្ធិ, ព្រះកែវ, ព្រះគោ, រូបសត្វទីទៃជាច្រើន និងព្រះសង្ឃសមណ: ឲនាំយកទាំងពញាកែវ ពញាទ័យ ជាព្រះរាជបុត្រ នៃព្រះបាទធម្មាសោករាជ (ស្ដេចខ្មែរសុគតក្នុងបន្ទាយ មហានគរ ក្នុងគ្រាធ្វើសង្គ្រាមនឹងសៀម ជំនាន់

នោះ) និង ទ្រង់ចៅក្បៀរគ្រួខ្មែរ បានចំនួន៧ម៉ឺននាក់ ហើយ ចលើកទ័ពទៅក្រុងស្រីអយុធ្យាវិញ។
ក្នុងឯកសារនេះដែរ បានសរសេរថា ស្តេចខ្មែរដែលថយ ព្រះតេជានុភាព បណ្តាលមកពីគ្មានបុត្រក្សត្រគឺ ព្រះបាទ សេណរាជ (ស្តេច ដែលតាត្រសក់ផ្អែមបានធ្វើឃាត)។ រៀង មកទៀត ព្រះមហាក្សត្រខ្មែរ មានតេជានុភាពត្រឹមត្រូវ ឡើងវិញ ទាល់តែមកដល់ព្រះចៅសៀមមកវាយ បែកព្រះ នគរ បន្ទាយលង្វែក នៅឆ្នាំ ១៥៩៤។
ត្រឡប់មកនិយាយអំពីគំនិត « រដ្ឋ-ប្រជាជាតិ », អំណាច អធិរាជ ត្រូវការ ជាចំបាច់ មានកម្លាំងកងទ័ពច្រើន, មានអនុភាព សំរាប់ត្រួតត្រាទឹកដី ដ៏ធំទូលំទូលាយមួយ ហើយ ត្រូវការ ស្វាមីភក្តិដាច់ខាត ពីសំណាក់ មេដំបន់និមួយៗ ឬ ចៅហ្វាយស្រុក។ បើគ្មានវត្ថុធាតុទាំងពីរនេះទេ គឺច្បាស់ជា អំណាចអធិរាជនេះ មិនអាចរស់នៅគង់វង់ បានយូរនោះឡើយ។ បើយោងតាមប្រវត្តិសាស្ត្រ, ស្រុកខ្មែរ ជា « រដ្ឋ-ប្រជាជាតិ » (ផ្តុំ ១៥៥ រដ្ឋតូចៗ) មានរដ្ឋធំពីរ ជា រដ្ឋអ្នកធ្វើសមោធាន (អ្នកប្រមូលចមានតែមួយ) ជា ដំបូង គឺ នគរភ្នំ (ហ្វូណន់) បន្ទាប់មក គឺ នគរចេនឡា (ជាន់លើ) : តាមទស្សនៈ របស់ភិក្ខុតោប៉ាងខាត់[4], ក្រោយ ពីបាន បង្រួបបង្រួម នគរទាំងពីរនេះចទៅតែមួយ, ខ្មែរ ដាក់ឈ្មោះនគរថា : កម្ពុជា, តាមរឿងព្រេងខ្មែរ ពាក្យកម្ពុ

[4] (ដកស្រង់ពីសៀវភៅប្រទេសខ្មែររបស់សមាគម Promo Khmer។

ជា កើតចេញមកពីពាក្យ ឥសីកម្ពុ (ស្វយម្ភូវ) ព្រោះកាលដែល ឥសីកម្ពុ បាននាងអប្សរា « មេរា » ជាភរិយា ក៏បានកើតទៅជា វង្សមួយ ខាងនគរចេនឡា ហៅថា សូរ្យវង្ស។ តាមប្រវត្តិសាស្ត្រ ការសម្ព័ន្ធ « កម្ពុ-មេរា » នេះ ប្រសូត្របាន បុត្រពីរព្រះអង្គ ហៅថា កម្ពុជៈ, បុត្រកម្ពុ គឺ ស្រុតវរ្ម័ន និង ស្រេស្ឋវរ្ម័ន សោយរាជ្យ ខាងចេនឡាជាប់រៀងមក។ ដើមឡើយគេមិនសូវឃើញមានប្រើពាក្យកម្ពុជៈនេះទេ, តែកាលព្រះបាទជ័យវរ្ម័នទី២ (៨០២,៨៥០) ឡើងគ្រងរាជ្យ មានអំណាចខ្លាំងពូកែ, ព្រះអង្គ បានរួបរួម ចេនឡាដីគោក និង ចេនឡាទឹក ជាប្រទេសមានឯកភាព ជារដ្ឋតែមួយ ហើយទើបឃើញមាន សិលាចារឹតប្រើពាក្យ កម្ពុជទេស ឬ កម្ពុទេសៈ,ប្រទេស នៃបុត្រកម្ពុ។ តែទោះបីយ៉ាងណាក៏ដោយ, ខ្មែរនៅតែហៅ នគរខ្លួនថា « ស្រុកខ្មែរ » ជានិច្ច ដែលជាប្រទេស របស់អំបូរ « ខ្មែរ-មន »។

ជាតុជា « រដ្ឋ-ប្រជាជាតិ » ជាប្រទេសរួម នូវរដ្ឋជាច្រើន មានការពិបាកច្រើន ក្នុងការស្វែងរក នៃអត្តសញ្ញាណរួម ដើម្បី ទុកជាតម្លៃរួម (ព្រលឹងជាតិ) សំរាប់បង្កើត នូវកម្លាំងរួម។ ដើម្បីការពារតម្លៃរួមនោះ, ព្រះបាទជ័យវរ្ម័នទី២ ទ្រង់បានស្វែងរកតម្លៃរួម ដោយយកតួ « អង្គស្ដេច » ឲទៅជា « ស្ដេចអាទិទេព » ដែលជាមហាក្សត្រ មានអំណាចអាណាចក្រ និង វេហាចក្រ ឋិតនៅពីលើស្ដេចរដ្ឋ

ទាំងឡាយ ដែលជា ស្តេចចំណុះ។ យើងដឹងថា លទ្ធិទេវរាជ នេះ អាចមានប្រសិទ្ធិភាពលុះត្រាតែ មហាក្សត្រនោះ ជាស្តេចយោធិន ល្បីខាងធ្វើ និង ឈ្នះសង្គ្រាមគ្រប់សមរភូមិ ដូចករណីព្រះបាទជ័យវរ្ម័នទី២នោះឯង។ បើនិយាយឲក្លីគឺ ត្រូវមានកម្លាំងទ័ពជាអចិន្ត្រៃយ សំរាប់រក្សាមហានគរ និង អំណាចមជ្ឈឹម ឲបានគង់វង់។ បើគ្មានកម្លាំងទ័ពនេះ គឺច្បាស់ជាបាត់គ្រឹះ សំរាប់ការពារ នូវឯកភាព នៃនគរ ហើយ វានាំបង្កើត នូវអនាធិបតេយ្យពេញផ្ទៃនគរជាពុំខាន។

យើងលើកយកករណី ព្រះបាទជ័យវរ្ម័នទី៧ មកបង្ហាញពីការស្វែងរក នូវតម្លៃរួមជាតិ ឬ ព្រលឹងជាតិ ផ្ទុយស្រឡះពីព្រះបាទជ័យវរ្ម័នទី២។ យើងដឹងថា ព្រះបាទជ័យវរ្ម័នទី៧ នោះបីព្រះអង្គជា ស្តេចយោធិន, ឈ្នះសង្គ្រាមក៏ដោយ, តែទ្រង់យល់ឃើញថា លទ្ធិ « ស្តេចអាទិទេព » លែងមានឥទ្ធិពល សំរាប់ដឹកនាំទៀតហើយ, ដូច្នេះ ទ្រង់បង្កើត នូវលទ្ធិដឹកនាំថ្មីមួយ ដោយយក « អង្គស្តេច » ជាអ្នកដឹកនាំមាន អំណាចរតនៈសម្បត្តិ (Pouvoir charismatique) មានសីលធម៌ និងមេត្តាធម៌។ ក្នុងលទ្ធិថ្មីនេះ, ទ្រង់យកពុទ្ធសាសនា ជាគ្រឹះ ព្រោះជា សាសនា របស់ប្រជារាស្ត្រ។ ដើម្បីបង្ហាញ នូវទឹកចិត្តព្រះអង្គក្នុងលទ្ធិនេះ, ព្រះអង្គបញ្ជាឲកសាងប្រាសាទបាយ័ន សំរាប់តំកល់ នូវបដិមាពុទ្ធរាជអង្គយ៉ាងធំ (កំពស់ជិត៤ម.) និង កសាងមន្ទីរពេទ្យ

១០២ សំរាប់ព្យាបាលជម្ងឺ ប្រជារាស្ត្រគ្រប់ស្រទាប់ នៅក្នុងព្រះនគរ។ គួរយើងដឹងដែរថា ក្នុងសតវត្សទី១៣, នៅទ្វិបឥណ្ឌា, ត្រូវជនជាតិកាន់សាសនាអ៊ីស្លាម បានជ្រៀតចូល ហើយ ធ្វើចម្បាំងឈ្នះ ហើយ ត្រួតត្រាទ្វិបឥណ្ឌាតែម្តង នៅអំឡុងឆ្នាំ១២០៩ (ឆ្នាំដែលពួកអ៊ីស្លាម បង្កើត រដ្ឋអ៊ីស្លាមមួយ ដែលមានឈ្មោះថា ក្រុងដេលី ធ្វើជារាជធានី)។ ការកាន់កាប់នេះ មានភាពហិង្សាណាស់, ពួកអ្នកឈ្នះបានដុត វិហារព្រហ្មញ្ញសាសនា និង សម្លាប់យ៉ាងឃោរឃៅបំផុត ពួកអ្នកកាន់សាសនានេះ និង ចាប់ស្ត្រីធ្វើជា ទាសី។ ប្រទេសឥណ្ឌា នៅក្នុងពេលនោះ ត្រូវពួកអ្នកឈ្នះ បង្ហិនបង្ហោចយ៉ាងខ្លោចផ្សា។ ស្ថានការណ៍មិនល្អនៅប្រទេសឥណ្ឌានេះ អាចឲយើង ធ្វើការស្មានបានថា នៅប្រទេសកម្ពុជា នៅរយៈពេលនោះ មានការថយឥទ្ធិពលពួកព្រាហ្មបុរោហិតយ៉ាងខ្លាំង ទៅលើវណ្ណៈអ្នកដឹកនាំខ្មែរ : ឧទាហរណ៍ដូចយ៉ាងការដូរ របបនយោបាយទេវរាជ មកជារបបនយោបាយពុទ្ធរាជ។ ការបង្កើត នូវតម្លៃរួម សំរាប់ជាតិ ឬព្រលឹងជាតិ ដោយយក ពុទ្ធសាសនាជាគ្រិះ, តម្រូវឲយើងធ្វើការពិចារណាលើ ធាតុពុទ្ធសាសនា ក្នុងលទ្ធិដឹកនាំខ្មែរដែលមានរៀបរាប់ខាងក្រោមនេះ។

យើងដឹងថា ពុទ្ធសាសនា ជាសាសនា ដើម្បីបុគ្គល, ជាផ្លូវសំរាប់បុគ្គលម្នាក់ ស្វែងរកសុខ សំរាប់អាត្មា, ធ្វើធម៌ ដើម្បីឲរួចចេញពី កង់ចក្រជីវិតសត្វលោក គឺខំកសាងបុណ្យ

ដើម្បី ឈប់ឲកើតមានជីវិតជាសត្វលោក ដែលយើងហៅផ្លូវទៅរកឋាននិព្វាន។ រួមសេចក្ដីមក, ពុទ្ធសាសនា មិនអាចជា លទ្ធិសំរាប់បង្រួបបង្រួម នូវតម្លៃរួមបាននោះឡើយ ព្រោះថា គុណូបការ កើតមកពីការធ្វើបុណ្យ គឺសំរាប់តែបុគ្គលម្នាក់ដែលគេខំកសាង សំរាប់តែអាត្មាតែប៉ុណ្ណោះ : ឧទាហរណ៍ គឺថា « បុគ្គលម្នាក់ពុំអាចធ្វើបុណ្យសំរាប់បុគ្គលម្នាក់ទៀត ឬ សំរាប់ក្រុមមនុស្សមួយ ឬ ប្រជាពលរដ្ឋប្រទេសមួយ ឲបានទទួលផល ពីបុណ្យរបស់ខ្លួនបានឡើយ »។ តែប្រជារាស្ត្រ អាចទាញប្រយោជន៍ពីលទ្ធិនយោបាយពុទ្ធរាជបានគឺ សេចក្ដីអាសូរ និង មេត្តាធម៌របស់អ្នកដឹកនាំ លើទុក្ខវេទនារបស់ខ្លួន។ មេត្តាធម៌នេះនាំបន្ថយចិត្តអ្នកដឹងនាំ ក្នុងគំនិតជិះជាន់ និង ឆ្លៀតរកប្រយោជន៍លើកម្លាំងរាស្ត្រ។ ហេតុនេះ បានជា លទ្ធិនយោបាយពុទ្ធរាជ មាន ជោគជ័យណាស់ ក្នុងចំណោមប្រជារាស្ត្រ : « បើស្ដេចមានចរិតស្លូតបូត គឺច្បាស់ ជារាស្ត្របានសុខ, តែបើស្ដេចមានចរិតពាល គឺច្បាស់ ជានគររលាយហិនហោច »។

ក្នុងប្រវត្តិសាស្ត្រខ្មែរ, យើងដឹងថា ព្រះបាទជ័យវរ្ម័នទី៨ (១២៤៣-១២៩៥) ជាស្ដេច ទទួលខុសត្រូវធំ ក្នុងរឿងប្រតិកម្មប្រឆាំងនឹងពុទ្ធសាសនា ព្រោះព្រះអង្គ ជាអ្នកធ្វើអនុគ្រោះ សាជាថ្មីឡើងវិញ ឲពួកព្រាហ្មបុរោហិត មានឥទ្ធិពលលើ នយោបាយដឹកនាំជាតិ។ ក្នុងរជ្ជកាល របស់ព្រះ

អង្គ ទ្រង់បានផ្លាស់ប្តូរ នូវរបបនយោបាយពុទ្ធរាជ មក នេះវិញ ដែលនាំឲមាន អាស្រូវបារាយកេរ្តិ៍ ដល់ការដឹកនាំ របស់ព្រះអង្គ, មិនតែប៉ុណ្ណោះ ការប្រែប្រួលនេះទៀត នាំឲមានការបែកបាក់ក្នុងវណ្ណៈអ្នកដឹកនាំ និងការបះបោរ នៃរដ្ឋចំណុះជាច្រើន ដែលជារដ្ឋនិយមពុទ្ធសាសនា ជាអាថិ គឺរដ្ឋនៅក្នុងប្រទេសសៀម និង លាវបច្ចុប្បន្ន ដែលខ្មែរហៅថា ខ្មែរលើ (ចេនឡា) ដែលប្រជារាស្ត្រ តែងតែគោរពពុទ្ធសាសនា តាំងពីបុរាណកាលមកម្លេះ។ ស្តេចខ្មែរសោយរាជ្យបន្តពីព្រះបាទជ័យវរ្ម័នទី៨ គឺព្រះបាទឥន្ទ្រវរ្ម័នទី៣ (១២៩៥-១៣០៧), ព្រះបាទឥន្ទ្រវរ្ម័នទី៤ (១៣០៧-១៣២៧), ព្រះបាទជ័យវរ្ម័នទី៩ (១៣២៧-១៣៤០), មានការជួបប្រទះនឹងវិបត្តិនយោបាយផ្ទៃក្នុងច្រើន ក្នុងការដឹកនាំជាតិ។ ស្រុកខ្មែរ បាត់ នូវឯកភាពដោយសារ អំណាចកណ្តាល បាត់ នូវអនុភាព ជាអំណាចឯកសមោធាន។ ភាពចលាចល និង អនាធិបតេយ្យ ក្នុងអាណាចក្រ កាន់តែមានច្រើនឡើងៗ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៩ ដែលជា ស្តេចចុងក្រោយបំផុត នៃសន្តិវង្សមហានគរ។ ហេតុនេះឯង បានជាមានកើតបដិវត្តន៍វាំង នាំអោយមានឃាតកម្ម សម្លាប់ស្តេច ពីសំណាក់ សេនាបតីមន្ត្រី។

ដូចបានរៀបរាប់ខាងលើរួចមកហើយ (យោងលើឯកសារលោក អេង សុត, ដកស្រង់ពីពង្សាវតារខ្មែរ), ព្រះបាទសេ

ណរាជ ព្រះបាទជ័យវរ្ម័នទី៩ បានចាកចេញពីមហានគរ មកតាំងរាជធានីនៅភ្នំប្រសិទ្ធិ។ បើតាមការយល់ របស់ យើង, ការបោះបង់ចោលនេះ គឺគ្មានអ្វីក្រៅពី ការរត់ គេចពី ការបេះបាលប្រឆាំងនឹងព្រះអង្គនោះឡើយ, តែ ព្រះអង្គ បានជួបនឹងអភ័ព្វថ្មី គឺមករស់នៅ ក្នុងដំបន់ មួយ ដែលប្រជារាស្ត្រ ជាអ្នកស្រឡាញ់ពុទ្ធសាសនាខ្លាំង ហើយ ជាពិសេសមាន អ្នកឧបត្ថម្ភសាសនាដ៏ឆ្នើមមួយ គឺ តាត្រសក់ផ្អែម ដែលជាមនុស្សម្នាក់ ប្រកបដោយ គតិបណ្ឌិតគួរឲគោរព។ សេនាបតីមន្ត្រីមួយក្រុម ដែល ស្រឡាញ់ពុទ្ធសាសនា មើលឃើញគុណសម្បត្តិតាត្រសក់ ផ្អែមនេះ បានរួមគំនិតគ្នាក្បត់នឹងមហាក្សត្រ ដោយយក តាត្រសក់ផ្អែម ដែលជា បុគ្គលមានប្រជាប្រិយភាពណាស់ ឲជាអ្នកដឹងនាំកំពូល នៃបដិវត្តន៍វាំងមួយ គឺការធ្វើឃាត ព្រះមហាក្សត្រ តាមផ្លូវសម្ងាត់។ តាមការយល់របស់យើង, ព្រះបាទសេណរាជ ត្រូវបានសេនាបតីព្រះអង្គ ធ្វើឃាតព្រះ អង្គនៅក្នុងព្រះរាជវាំង, ហើយនាំគ្នាយកសពព្រះអង្គ ទៅ ចោល ក្នុងចំការត្រសក់ របស់តាត្រសក់ផ្អែម, ហើយនាំគ្នា បង្កើតរឿងស្តេចទៅឃ្លាំមើលតាត្រសក់ផ្អែម ក្រែងគាត់ លួចលក់ត្រសក់ឲជនឯទៀត ខុសពីបំរាម របស់ព្រះអង្គ, ហើយ ត្រូវបានម្ចាស់ចំការ ធ្វើឃាតដោយថៃដន្យនោះ ទៅ។ យើងយល់ឃើញថា ទោះបី តាត្រសក់ផ្អែម ចូលរួម ចំណែកយ៉ាងសកម្ម ក្នុងរឿងក្បត់ស្តេចនេះក៏ដោយ, គាត់

ច្បាស់ជាប្រាប់ពួកសេនាបតីថា គាត់មិនព្រមធ្វើឃាតស្ដេចដោយផ្ទាល់ដៃគាត់នោះឡើយ ព្រោះគាត់ ជាអ្នកកាន់ពុទ្ធសាសនា, ដូច្នេះរឿងធ្វើឃាត គឺជាកិច្ចការ របស់ពួកសេនាបតី, ចំណែកគាត់ គឺជាអ្នកបញ្ឆោះបញ្ឆូល និងពន្យល់ប្រជារាស្ត្រថា ឃាតកម្មស្ដេចនេះ ជាឃាតកម្មដោយជួន ដែលជាកម្មផល របស់ព្រះបាទសេណរាជតែប៉ុណ្ណោះ។

យើងដឹងហើយថា ទីបញ្ចប់ នៃសន្តវង្សអង្គរ ក៏ជាទីបញ្ចប់ជាស្ថាពរ នៃលទ្ធិទេវរាជនោះដែរ។ ចាប់តាំងពីរជ្ជកាលព្រះបាទតាត្រសក់ផ្អែមមក រហូតមកដល់ សម័យសង្គមនិយម, លទ្ធិនយោបាយខ្មែរ តែងយក ពុទ្ធសាសនា ជាគ្រឹះជាតិ។ របបរាជានិយម បានយកបាវចនា « ជាតិ, សាសនា និង មហាក្សត្រ » ជាព្រលឹងជាតិ។ យើងសួរថា តើបាវចនានេះ ជាកត្តាបង្រួបបង្រួមជាតិខ្មែរបានដែរឬទេ ? តើជា បាវចនាថាមវន្ត (dynamique) ឬ ឋិតវន្ត (statique) ?

ការយក រូបអង្គរវត្ត ជាអត្តសញ្ញាណជាតិ តើសំរាប់គ្រាន់តែជាការរំលឹក នៃអនុស្សាវរីយ៍ នៃសេចក្ដីថ្កុំថ្កើងខ្មែរពីអតីតកាល ឬជា មាគ៌ា សំរាប់ខ្មែរដើរ ទៅរកសេចក្ដីចំរើនជាតិក្នុងគតិថ្មី ដែលប្រកបដោយ នវភាព (ភាពទំនើប) និងលទ្ធិប្រជាធិបតេយ្យសេរី ?

តាមការសំគាល់ឃើញ នៃវិបន្តធំខ្មែរបច្ចុប្បន្ន, យើងយល់ឃើញថា ព្រលឹងជាតិ ឈរលើបាវចនា « ជាតិ, សាសនា, មហាក្សត្រ » មិនពិតជាមាគ៌ា សំរាប់សង្គ្រោះជាតិខ្មែរ បាននោះឡើយ, បើអ្នកដឹកនាំខ្មែរ នៅតែរក្សាចរិតខ្លួន ជាអ្នកសោយសម្បត្តិ តាមអំណាចរបស់ខ្លួននិង ក្រាញក្នុងអំណាច ដើម្បីអញ។ ទោះបីប្រជាជាតិខ្មែរធ្លាប់ស្គាល់ សេចក្តីរង់រឿងយ៉ាងណាក៏ដោយ, តែបើតាមការសង្កេតមើល របស់យើង, យើងយល់ឃើញថា ខ្មែរមិនដែលធ្លាប់មានព្រលឹងជាតិ មានមូលដ្ឋានចេញពី ប្រជារាស្ត្រពិតប្រាកដនោះទេ ព្រោះទី១, ប្រជាជាតិយើងជា « រដ្ឋ-ប្រជាជាតិ », ទី២, សេចក្តីថ្កុំថ្កើងរបស់ជាតិខ្មែរ គឺឈរលើកម្លាំងយោធា ដែលជា អំណាចបង្ខំ, អំណាចនេះ មិនត្រឹមតែបង្ខំ ឲនគរចំណុះខ្លាចតែប៉ុណ្ណោះទេ, គឺបង្ខំឲប្រជាពលរដ្ឋខ្លួនឯង ខ្លាចដូចគ្នាដែរ។ ក្នុងអំណាចបង្ខំនេះ, អ្នកដឹកនាំជាតិខ្មែរ ទុកខ្លួនជា ព្រលឹងជាតិ ហើយ ទុកប្រជាពលរដ្ឋខ្លួនឯង ជាសត្រូវធំ របស់ខ្លួន មុនសត្រូវមកពីក្រៅប្រទេស, ដូចក្នុងសង្គ្រាមចន្លោះ ឆ្នាំ១៩៧០ និង ១៩៧៥, ពួកខ្មែរក្រហម បានទុក របបសាធារណរដ្ឋ ជាសត្រូវទី១ នៅចំពោះមុខខ្មាំងជាតិ គឺយួនកុម្មុយនិស្ត, មិនត្រឹមតែប៉ុណ្ណោះ ពេលពួកនោះបានអំណាច, គឺគេទុកប្រជាពលរដ្ឋ ជាសត្រូវ របស់អំណាច របស់ខ្លួន។ លោក វាន់ឌី កាអុន, អ្នកគតិបណ្ឌិតខ្មែរម្នាក់, ធ្លាប់បានសរសេរថា :

« នយោបាយខ្មែរឥតរាស្ត្រខ្មែរ », សំណេរនេះ ជាការសង្ខេបដ៏ត្រឹមត្រូវមួយ របស់ចិត្តគំនិតអ្នកដឹកនាំខ្មែរគ្រប់សម័យ និង គ្រប់ស្រទាប់ គឺគាត់មិនដែលយកប្រជារាស្ត្រ ជាគោលប្រយោជន៍ជាតិនោះឡើយ។ របបខ្មែរក្រហម និង របបបច្ចុប្បន្ន, សុទ្ធតែពូជរាស្ត្រ ជាអ្នកដឹកនាំ (ប៉ុលពត, ហ៊ុនសែន), តែមិនពិតជាពួករាស្ត្រនេះ ស្រឡាញ់ប្រជារាស្ត្រខ្មែរ ដែលជា ប្រភពកំណើត របស់ខ្លួននោះឡើយ, មិនតែប៉ុណ្ណោះ, ពួកអ្នកដឹកនាំសព្វថ្ងៃ គេនាំគ្នាពាក់ងារ ដែលមានក្នុងរបបសក្តិភូមិ ដើម្បីឲប្រជារាស្ត្របំភ្លេច នូវដើមកំណើតជារាស្ត្ររបស់ខ្លួន។

អំណាចនៅស្រុកខ្មែរ មិនមែនជារឿងវណ្ណៈនោះឡើយ, វាជា វប្បធម៌ដុះស្លែមួយ ក្នុងសង្គមខ្មែរ ដែលនាំឲអ្នកដឹកនាំគ្រប់វណ្ណៈ ពេលណាខ្លួនមកកាន់អំណាច គឺត្រូវតែបន្ត នូវវប្បធម៌ចង្រៃនេះតទៅទៀត គឺធ្វើនយោបាយគ្មានរាស្ត្រ ដូចជាការយល់ឃើញ របស់លោក វ៉ាន់ឌី កាអុននោះឯង។ រួមសេចក្តីមក, បើអ្នកដឹកនាំឥតរាស្ត្រ គឺពិតជាឥតមានព្រលឹងជាតិពិតនោះឯង។ ដូច្នេះ, បាវចនា « ជាតិ, សាសនា និង ព្រះមហាក្សត្រ » គឺគ្រាន់ជាពាក្យ សំរាប់អ្នកដឹកនាំ យកមកច្រៀង សំរាប់ឲតែពីរោះត្រចៀកខ្លួនឯងតែប៉ុណ្ណោះ ព្រោះថាខ្លួន ឥតត្រូវការឲរាស្ត្រស្តាប់នោះឡើយ។ សួរថា តើព្រលឹងជាតិខ្មែរពិតគឺអ្វី ? ចំពោះយើង ព្រលឹងជាតិ គឺប្រជារាស្ត្រខ្មែរនោះឯង ដែលជា

ពលរដ្ឋ មានការទទួលខុសត្រូវ លើជោគវាសនា របស់ខ្លួន។ តែបើ ប្រជារាស្ត្រខ្មែរ មិនព្រមប្រើសិទ្ធិខ្លួន ជាពលរដ្ឋ គឺ ប្រជាជាតិ មិនអាចរកឃើញ នូវព្រលឹងជាតិខ្មែរបាន ជាដាច់ខាត។ ពួកអ្នកដឹកនាំសព្វថ្ងៃ កំពុងប្រព្រឹត្តអំពើអាក្រក់ដល់ជាតិ តែបើប្រជារាស្ត្រ នាំគ្នានៅស្ងៀម គឺ ប្រជារាស្ត្រនោះឯង ជាអ្នកទទួលខុសត្រូវ ព្រោះ ខ្លួនជាប្រជាជាតិ មានព្រលឹងជាតិ៕